**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២១៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីគោលការណ៍ វិធាន និងសមត្ថកិច្ចនៃការគ្រប់គ្រងវិសាលគមន៍ប្រេកង់វិទ្យុ និងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណប ក្នុងគោលបំណងរៀបចំ បែងចែក និង

ប្រើប្រាស់ប្រេកង់វិទ្យុឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ដើម្បីពង្រឹងការគ្រប់គ្រងនិងការប្រើប្រាស់ធនធានកម្មសិទ្ធិរបស់ជាតិ ការចូលរួមប្រកួតប្រជែងដោយស្មោះត្រង់និងស្របច្បាប់ និងការរួមចំណែកដល់ការកៀរគរចំណូលជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិសាលគមន៍ប្រេកង់វិទ្យុនិងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណបដែលស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែវិស័យសន្តិសុខនិងការពារជាតិ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរកាត់ថា **ក.ប.ទ.** ជាស្ថាប័នមានសមត្ថកិច្ចលើការគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ បន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណប និងគន្លងផ្កាយរណបនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងមានអង្គភាពទទួលបន្ទុកគ្រប់គ្រងធនធានវិសាលគមន៍ប្រេកង់វិទ្យុ ជាសេនាធិការក្នុងការរៀបចំ ការគ្រប់គ្រង និងការបែងចែកធនធានវិសាលគមន៍ប្រេកង់វិទ្យុ បន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណប និងគន្លងផ្កាយរណបនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការសម្របសម្រួលជាអន្តរជាតិលើការប្រើប្រាស់ប្រេកង់វិទ្យុនិងការចុះបញ្ជីជាតិប្រេកង់វិទ្យុទៅក្នុងបញ្ជីអន្តរជាតិគោលប្រេកង់វិទ្យុ។

និយ័តករទូរគមនាគមន៍កម្ពុជា សរសេរកាត់ថា **ន.ទ.ក.** មានសមត្ថកិច្ចធ្វើនិយ័តកម្មធនធានវិសាលគមន៍ប្រេកង់វិទ្យុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ **ន.ទ.ក.** អាចស្នើសុំរដ្ឋមន្ត្រី **ក.ប.ទ.** ដើម្បីឱ្យមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តបំពេញភារកិច្ចណាមួយនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តនីមួយៗ។

**មាត្រា៥ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងព័ត៌មាន ក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់របាយការណ៍អំពីការប្រើប្រាស់ប្រេកង់វិទ្យុប្រចាំឆ្នាំជូន **ក.ប.ទ.** នៅសប្តាហ៍ទី១នៃខែធ្នូ សម្រាប់ជាធាតុចូលក្នុងការរៀបចំ ការគ្រប់គ្រង និងការបែងចែកធនធានវិសាលគមន៍ប្រេកង់វិទ្យុ និងការធ្វើបច្ចុប្បន្នកម្មនៃផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ។ ទម្រង់បែបបទនៃរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៣
## គោលការណ៍នៃការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ

**មាត្រា៦ .-**

ការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក- ការវិវឌ្ឍនៃបច្ចេកវិទ្យា។

ខ- តម្រូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមរបស់ព្រះរាជាណាចក្រកម្ពុជា។

គ- ការមិនឆ្លងរំខានដល់ការទទួលស៊ីញ៉ាល់។

ឃ- ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ។

ង- ការប្រកួតប្រជែងដោយស្មោះត្រង់និងស្របច្បាប់និងប្រកបដោយប្រសិទ្ធភាពក្នុងវិស័យទូរគមនាគមន៍។

ច- សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

ឆ- អនុលោមភាពតាមបទដ្ឋានអន្តរជាតិនៃការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ។

## ជំពូកទី៤
## ការរៀបចំផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ

**មាត្រា៧ .-**

ផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ត្រូវរៀបចំដោយរួមបញ្ចូលតារាងជាតិបែងចែកហ្វ្រេកង់ស៍វិទ្យុ តារាងពិពណ៌នាហ្វ្រេកង់ស៍វិទ្យុ និងផែនការបន្ទារហ្វ្រេកង់ស៍វិទ្យុ។ ការរៀបចំនិងការបែងចែកវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ត្រូវគោរពតាមផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ។ ផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុត្រូវសម្រេចដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

ការរៀបចំផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុត្រូវ៖

ក- បែងចែកជាបន្ទារហ្វ្រេកង់ស៍វិទ្យុ ដោយបញ្ជាក់កម្មវត្ថុនៃការប្រើប្រាស់ច្បាស់លាស់ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍។

ខ- កំណត់អំពីវិធីសាស្ត្រនៃការបែងចែកនិងការបែងចែកឡើងវិញនូវវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ព្រមទាំងការប្រើប្រាស់និងការកែប្រែការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ ស្របតាមការវិវឌ្ឍនៃបច្ចេកវិទ្យា។

គ- អនុលោមតាមបទដ្ឋានអន្តរជាតិនានាពាក់ព័ន្ធនឹងការបែងចែកវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុដែលកំណត់ដោយសហភាពទូរគមនាគមន៍អន្តរជាតិ។

ឃ- ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។

ការបែងចែកជាបន្ទារហ្វ្រេកង់ស៍វិទ្យុដូចមានកំណត់ក្នុងចំណុច ក នៃកថាខណ្ឌទី២ ត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក- បន្ទារហ្វ្រេកង់ស៍វិទ្យុដែលបម្រុងទុកសម្រាប់វិស័យសន្តិសុខនិងការពារជាតិ។

ខ- បន្ទារហ្វ្រេកង់ស៍វិទ្យុដែលបម្រុងទុកនិងផ្តល់ជាអាទិភាពសម្រាប់ផលប្រយោជន៍សាធារណៈ សហគមន៍ ឬសេវាគ្រាអាសន្ន។

គ- បន្ទារហ្វ្រេកង់ស៍វិទ្យុដែលកំណត់សម្រាប់សេវាសោតទស្សន៍ សេវាអាកាសចរណ៍ស៊ីវិល សេវានាវាចរណ៍ ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងសេវាផ្សេងទៀត ស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

ឃ- បន្ទារហ្វ្រេកង់ស៍វិទ្យុបម្រុងដែលកំណត់សម្រាប់ការប្រើប្រាស់នាថ្ងៃអនាគត។

**មាត្រា៨ .-**

ក្នុងករណីចាំបាច់ **ក.ប.ទ.** អាចរៀបចំផែនការបន្ទារហ្វ្រេកង់ស៍វិទ្យុលម្អិតនិងដាច់ដោយឡែក ស្របតាមផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុឬតាមការចាំបាច់នៃការវិវឌ្ឍបច្ចេកវិទ្យានិងសុខដុមនីយកម្មក្នុងតំបន់ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន។

**មាត្រា៩ .-**

**ក.ប.ទ.** ត្រូវធ្វើបច្ចុប្បន្នកម្មនៃផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ យ៉ាងយូរ៥(ប្រាំ)ឆ្នាំម្តង ស្របតាមឬដោយពិចារណាអំពីការវិវឌ្ឍនៃបច្ចេកវិទ្យា តម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវិធានដែលត្រូវបានកំណត់ដោយសហភាពទូរគមនាគមន៍អន្តរជាតិ។

**ក.ប.ទ.** ត្រូវផ្សព្វផ្សាយជាសាធារណៈនូវផែនការជាតិវិសាលគមន៍ហ្វ្រេកង់វិទ្យុនិងព័ត៌មានដែលពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់វិទ្យុ។

# ជំពូកទី៥
# ការប្រើប្រាស់ហ្វ្រេកង់វិទ្យុ
## ផ្នែកទី១
## គោលការណ៍នៃការប្រើប្រាស់ហ្វ្រេកង់វិទ្យុ

**មាត្រា១០.-**

ការប្រើប្រាស់ហ្វ្រេកង់វិទ្យុ ត្រូវមានការអនុញ្ញាតជាមុនពី **និ.ទ.ក.** តាមរយៈការផ្តល់អាជ្ញាបណ្ណហ្វ្រេកង់វិទ្យុឬតាមរយៈការអនុញ្ញាតឱ្យប្រើប្រាស់ហ្វ្រេកង់វិទ្យុទូទៅ។

ការប្រើប្រាស់ហ្វ្រេកង់វិទ្យុសម្រាប់បម្រើដល់វិស័យទូរគមនាគមន៍និងផ្សព្វផ្សាយសោតទស្សន៍ជាអន្តរជាតិឬការប្រើប្រាស់សម្រាប់សេវាផ្សេងទៀត ទោះជាតាមរយៈស្ថានីយផ្កាយរណបលើដី និង/ឬគន្លងផ្កាយរណបអចល័តធៀបនឹងធរណី និង/ឬគន្លងផ្កាយរណបចល័តធៀបនឹងធរណី ត្រូវសម្រេចដោយរាជរដ្ឋាភិបាលផ្អែកតាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

ចំពោះការប្រើប្រាស់ហ្វ្រេកង់វិទ្យុសម្រាប់បម្រើដល់សេវាផ្សព្វផ្សាយសោតទស្សន៍ ក្រសួងព័ត៌មានមានសមត្ថកិច្ចចេញអាជ្ញាបណ្ណប្រតិបត្តិការសេវាផ្សព្វផ្សាយសោតទស្សន៍។ ចំពោះការសរសេរលេខហ្វ្រេកង់វិទ្យុឬលេខកាណាល់ក្នុងអាជ្ញាបណ្ណប្រតិបត្តិការសេវាផ្សព្វផ្សាយសោតទស្សន៍ ក្រសួងព័ត៌មានត្រូវពិភាក្សាជាមួយ **និ.ទ.ក.** ជាមុន ដើម្បីជៀសវាងការឆ្លងរំខាននិងប្រើប្រាស់បន្ទារហ្វ្រេកង់វិទ្យុត្រួតស៊ីគ្នា។

**មាត្រា១១.-**

អាជ្ញាបណ្ណហ្វ្រេកង់វិទ្យុដែលកំណត់ក្នុងអនុក្រឹត្យនេះ រួមមានអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុនិងអាជ្ញាបណ្ណបរិធានហ្វ្រេកង់វិទ្យុ។

អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុ ត្រូវផ្តល់ជូននីតិបុគ្គលសម្រាប់ប្រតិបត្តិការផ្តល់សេវាទូរសព្ទចល័តឬសេវាផ្សេងទៀត ស្របតាមការវិវឌ្ឍនៃបច្ចេកវិទ្យានិងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

អាជ្ញាបណ្ណបរិធានហ្វ្រេកង់វិទ្យុ ត្រូវផ្តល់ជូនបុគ្គលសម្រាប់ប្រតិបត្តិការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍និងប្រតិបត្តិការប្រើប្រាស់ហ្វ្រេកង់វិទ្យុ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា១២.-**

ការអនុញ្ញាតឱ្យប្រើប្រាស់ហ្វ្រេកង់វិទ្យុទូទៅ ត្រូវផ្តល់សម្រាប់បុគ្គលដែលប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ដោយអនុលោមតាមផែនការជាតិវិសាលគមន៍ហ្វ្រេកង់វិទ្យុនិងគោលការណ៍ ដូចខាងក្រោម៖

ក- ការធ្វើនិយ័តកម្មលើប្រតិបត្តិការពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់វិទ្យុមានចរិតលក្ខណៈតិចតួចឬមិនចាំបាច់។

ខ- គោលបំណងនៃការប្រើប្រាស់ហ្វ្រេកង់វិទ្យុសម្រាប់ការពិសោធឬការប្រើប្រាស់ហ្វ្រេកង់វិទ្យុបណ្តោះអាសន្ន។

គ- ហ្វ្រេកង់វិទ្យុដែលត្រូវប្រើប្រាស់ជាក់លាក់និងត្រូវស្របតាមបទប្បញ្ញត្តិអន្តរជាតិ។

ឃ- ហានិភ័យនិងទំហំនៃការឆ្លងរំខានតិចតួចបំផុត។

ង- ទំហំនៃការគ្របដណ្តប់ដោយសេវារបស់ប្រតិបត្តិការមានរយៈចម្ងាយខ្លី។

ក្នុងករណីមានការឆ្លងរំខានធ្ងន់ធ្ងរ **និ.ទ.ក.** មានសិទ្ធិព្យួរការប្រើប្រាស់ហ្វ្រេកង់វិទ្យុនោះ។

## ផ្នែកទី២
## លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណប្រេកង់វិទ្យុ

**មាត្រា១៣ .-**

អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវផ្តល់តាមរយៈការដេញថ្លៃប្រកបដោយតម្លាភាពឬតាមការសម្រេចដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

ក្នុងករណីបុគ្គលឈ្នះការដេញថ្លៃ មិនបង់ថ្លៃតាមតម្លៃដែលខ្លួនដេញថ្លៃបានទេ **ក.ប.ទ.** មានសិទ្ធិផ្ទេរទៅឱ្យបុគ្គលផ្សេងទៀត តាមតម្លៃដែលដេញថ្លៃបានដោយបុគ្គលឈ្នះការដេញថ្លៃនោះឬរៀបចំដេញថ្លៃសាជាថ្មីឡើងវិញក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ បន្ទាប់ពីការដាស់តឿនចុងក្រោយអំពីការបង់ថ្លៃ។

ក្នុងករណីដែលសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្រោមអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវបានដកហូត **ក.ប.ទ.** ត្រូវរៀបចំការដេញថ្លៃឡើងវិញ។

លក្ខខណ្ឌនិងនីតិវិធីនៃការដេញថ្លៃអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុត្រូវដាក់ពាក្យស្នើសុំនៅ **ន.ទ.ក.**។

**ន.ទ.ក.** មានសិទ្ធិប្តូរទីតាំងប្រេកង់វិទ្យុដែលបានផ្តល់ឱ្យអ្នកកាន់អាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុដែលបង្កការរំខានធ្ងន់ធ្ងរដល់ប្រតិបត្តិការទូរគមនាគមន៍និងការផ្សព្វផ្សាយសោតទស្សន៍ដទៃ បន្ទាប់ពីបានការអនុញ្ញាតពី **ក.ប.ទ.**។

## ផ្នែកទី៣
## សុពលភាពនៃអាជ្ញាបណ្ណប្រេកង់វិទ្យុ

**មាត្រា១៥ .-**

អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវមានសុពលភាពយ៉ាងយូរ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។ អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុដែលបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអាជ្ញាបណ្ណ លក្ខខណ្ឌ និងកាតព្វកិច្ចនានាដែលបានកំណត់ក្នុងអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត មានសិទ្ធិស្នើសុំបន្តការប្រើប្រាស់ប្រេកង់វិទ្យុតែមួយដងគត់ សម្រាប់រយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ ដែលរយៈពេលនេះមិនត្រូវហួសរយៈពេលសុពលភាពនៃអាជ្ញាបណ្ណប្រតិបត្តិការឡើយ។ អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុត្រូវដាក់ពាក្យស្នើសុំមក **ន.ទ.ក.** ឱ្យបាន១(មួយ)ឆ្នាំ មុនអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុនោះ ផុតសុពលភាព ដើម្បីអាចទទួលបានសិទ្ធិបន្តប្រើប្រាស់ប្រេកង់វិទ្យុនេះ។ **ន.ទ.ក.** មានរយៈពេល៣០(សាមសិប)ថ្ងៃបន្ទាប់ពីបានទទួលពាក្យស្នើសុំបន្តសុពលភាពដើម្បីស្នើសុំការសម្រេចពី **ក.ប.ទ.**។ អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ត្រូវបង់កម្រៃអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុដែលបានបន្តសុពលភាព។

ក្នុងករណីដែលមិនមានការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ **ន.ទ.ក.** ត្រូវរៀបចំរបាយការណ៍មក **ក.ប.ទ.** ដើម្បីដេញថ្លៃសាជាថ្មីក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ខែ។

**មាត្រា១៦ .-**

អាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ មានសុពលភាព១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។ អ្នកកាន់អាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុដែលបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអាជ្ញាបណ្ណ អាចដាក់ពាក្យស្នើសុំបន្តសុពលភាពមក **ន.ទ.ក.** ឱ្យបាន៦០(ហុកសិប)ថ្ងៃ មុនអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុនោះផុតសុពលភាព។

## ផ្នែកទី៤
## កម្រៃអាជ្ញាបណ្ណប្រេកង់វិទ្យុ

**មាត្រា១៧ .-**

កម្រៃអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ រួមមាន៖

ក- កម្រៃរដ្ឋបាលប្រចាំឆ្នាំ។

ខ- កម្រៃទទួលបានតាមរយៈការដេញថ្លៃ។

**មាត្រា១៨ .-**

កម្រៃអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ ត្រូវកំណត់ដោយផ្អែកលើគោលការណ៍ ដូចខាងក្រោម៖

ក- ចំនួនគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍។

ខ- ទំហំបន្ទារប្រេកង់វិទ្យុនិងអានុភាពផ្សាយ។

គ- វិសាលភាពដែនដី។

**មាត្រា១៩ .-**

ការអនុញ្ញាតឱ្យប្រើប្រាស់ប្រេកង់វិទ្យុទូទៅមិនតម្រូវឱ្យបង់កម្រៃទេ ប៉ុន្តែត្រូវអនុវត្តតាមកាតព្វកិច្ច ដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា២២នៃអនុក្រឹត្យនេះ។

**មាត្រា២០ .-**

ការប្រើប្រាស់ប្រេកង់វិទ្យុដោយផ្កាយរណបគ្រប់ប្រភេទត្រូវបង់កម្រៃសិទ្ធិប្រើប្រាស់ លើកលែងតែការប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់វិស័យសន្តិសុខនិងការពារជាតិ។

**មាត្រា២១ .-**

កម្រៃអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុនិងកម្រៃអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៥
## កាតព្វកិច្ចនៃការប្រើប្រាស់ប្រេកង់វិទ្យុ

**មាត្រា២២ .-**

អ្នកកាន់អាជ្ញាបណ្ណប្រេកង់វិទ្យុទាំងអស់ត្រូវបំពេញកាតព្វកិច្ច ដូចខាងក្រោម៖

ក- គោរពតាមលក្ខខណ្ឌដែលកំណត់ក្នុងអាជ្ញាបណ្ណនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ- ប្រើប្រាស់ប្រេកង់វិទ្យុប្រកបដោយប្រសិទ្ធភាព។

គ- គោរពតាមបែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់ប្រតិបត្តិការទូរសព្ទចល័ត ដូចមានចែងក្នុងមាត្រា៣០នៃអនុក្រឹត្យនេះ។

ឃ- គោរពតាមបែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការចែករំលែកសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុ ដូចមានចែងក្នុងមាត្រា២៥នៃអនុក្រឹត្យនេះ។

ង- គោរពតាមបែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការកែប្រែការប្រើប្រាស់ប្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរនៃបច្ចេកវិទ្យា ដូចមានចែងក្នុងមាត្រា៣៣នៃអនុក្រឹត្យនេះ។

ច- បង់កម្រៃអាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឆ- ប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ដែលមានវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនិងបិទតែមប្រើប្រតិវេទន៍បច្ចេកទេស ដូចមានចែងក្នុងមាត្រា៤២នៃអនុក្រឹត្យនេះ។

ជ- មិនបង្កការរំខានធ្ងន់ធ្ងរដល់ការទទួលស៊ីញ៉ាល់។

ឈ- ផ្តល់របាយការណ៍ស្តីពីការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុមក **ន.ទ.ក.** ក្នុងករណីមានការឆ្លងរំខានឬមានបណ្តឹងពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុដែលឆ្លងរំខាន។

ញ- ផ្តល់របាយការណ៍ស្តីពីការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ ដូចមានកំណត់ក្នុងអាជ្ញាបណ្ណ។

អ្នកប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ ដែលស្ថិតនៅក្រោមការអនុញ្ញាតឱ្យប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុទូទៅត្រូវគោរពតាមកាតព្វកិច្ច ដូចខាងក្រោម៖

ក- គោរពតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ។

ខ- ប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ដែលមានវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនិងបិទតែមប្រើប្រតិវេទន៍បច្ចេកទេស ដូចមានចែងក្នុងមាត្រា៤២នៃអនុក្រឹត្យនេះ។

គ- ផ្តល់របាយការណ៍ស្តីពីការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុមក **ន.ទ.ក.** ក្នុងករណីមានការឆ្លងរំខានឬមានបណ្តឹងពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុដែលឆ្លងរំខាន។

**មាត្រា២៣ .-**

ត្រូវចាត់ទុកជាការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុពុំមានប្រសិទ្ធភាព ជាអាទិ៍៖

ក- ការផ្អាកឬការឈប់ប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុក្នុងរយៈពេល២(ពីរ)ខែជាប់គ្នា ដោយពុំមានមូលហេតុត្រឹមត្រូវ។

ខ- ការផ្អាកឬការឈប់ប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុក្នុងរយៈពេលសរុបលើសពី១(មួយ)ឆ្នាំ ទោះបីជាទទួលបានការអនុញ្ញាតក៏ដោយ។

គ- ការប្រើប្រាស់បន្ទាហ្វ្រេកង់ស៍វិទ្យុដែលបានផ្តល់ឱ្យពុំអស់លទ្ធភាពក្នុងរយៈពេលចាប់ពី៦(ប្រាំមួយ)ខែជាប់ៗគ្នាឬការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុមិនគ្របដណ្តប់លើតំបន់ដូចដែលបានកំណត់នៅក្នុងផែនការធុរកិច្ចនិងផែនការបច្ចេកទេស។

**មាត្រា២៤ .-**

អ្នកប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុត្រូវសហការគ្នាដើម្បីផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងពេលមានគ្រាអាសន្នឬការស្វែងរកជំនួយសង្គ្រោះបន្ទាន់ ក្នុងករណីដូចខាងក្រោម៖

ក- ការប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ។

ខ- ការគំរាមកំហែងឬហានិភ័យដល់អាយុជីវិតឬគ្រោះថ្នាក់ដល់រាងកាយ។

គ- ការបាត់បង់ឬការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិសាធារណៈនិង/ឬទ្រព្យសម្បត្តិឯកជន។

ឃ- ការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។

ង- ការទទួលរងគ្រោះថ្នាក់ដោយយានយន្ត នាវា អាកាសយាន ឬគ្រោះមហន្តរាយ ជាដើម។

## ផ្នែកទី៦
## ការចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ

**មាត្រា២៥ .-**

ការចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ ត្រូវធ្វើតាមរយៈកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនិងមានការអនុញ្ញាតពី **ន.ទ.ក.**។

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ដែលមានបំណងចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុអាចចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុរបស់ខ្លួនបានតែជាមួយប្រតិបត្តិករទូរគមនាគមន៍ដែលមានអាជ្ញាបណ្ណប្រតិបត្តិការសេវាទូរសព្ទចល័តនិងត្រូវបំពេញរាល់លក្ខខណ្ឌ ដូចខាងក្រោម៖

ក- បរិមាណហ្វ្រេកង់ស៍វិទ្យុដែលចង់ចែករំលែកលើសពីតម្រូវការប្រតិបត្តិការ។

ខ- អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុទទួលបានតាមរយៈការដេញថ្លៃ។

គ- ហ្វ្រេកង់វិទ្យុដែលចង់ចែករំលែកត្រូវបានប្រើប្រាស់យ៉ាងតិចក្នុងអំឡុងពេល៥(ប្រាំ)ឆ្នាំ និងត្រូវបន្តអាជីវកម្មរបស់ខ្លួនជាធម្មតាបន្ទាប់ពីបានចែករំលែក ដោយត្រូវធានាការប្រើប្រាស់ហ្វ្រេកង់វិទ្យុដែលនៅសល់ប្រកបដោយប្រសិទ្ធភាព។

ឃ- ការអនុវត្តផែនការបច្ចេកទេសដែលភ្ជាប់ជាមួយអាជ្ញាបណ្ណបានយ៉ាងតិច៨០(ប៉ែតសិប)ភាគរយ។

ង- រយៈពេលនៃការចែករំលែកមិនត្រូវហួសពីសុពលភាពដែលកំណត់ក្នុងអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុនិងសុពលភាពដែលកំណត់ក្នុងអាជ្ញាបណ្ណប្រតិបត្តិការសេវាទូរសព្ទចល័តរបស់ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការចែករំលែក។

ច- យន្តការច្បាស់លាស់ក្នុងការគ្រប់គ្រងការឆ្លងរំខាន។

បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ**.។

**មាត្រា២៦ .-**

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុ ដែលមានបំណងចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយជាសាធារណៈអំពីព័ត៌មានលម្អិតនិងត្រឹមត្រូវនៃហ្វ្រេកង់វិទ្យុដែលចង់ចែករំលែក។

**មាត្រា២៧ .-**

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុ ដែលមានបំណងចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុឬប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័ត ដែលមានបំណងទទួលយកការចែករំលែកផ្នែកណាមួយនៃបន្ទារហ្វ្រេកង់វិទ្យុ ឬទទួលយកការចែករំលែកបន្ទារហ្វ្រេកង់វិទ្យុនៅតំបន់ភូមិសាស្ត្រណាមួយ ត្រូវដាក់ពាក្យស្នើសុំមក **ន.ទ.ក**. ដោយត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

ក- កិច្ចព្រមព្រៀងចែករំលែកហ្វ្រេកង់វិទ្យុ ត្រូវមានឈ្មោះនិងអាសយដ្ឋានរបស់ភាគី ទំហំ និងទីតាំងនៃបន្ទារហ្វ្រេកង់វិទ្យុ រយៈពេលដែលស្នើសុំចែករំលែក និងបច្ចេកវិទ្យានៃប្រតិបត្តិការទូរគមនាគមន៍របស់ភាគី។

ខ- ផែនការធុរកិច្ចនិងផែនការបច្ចេកទេសរបស់អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុដែលមានបំណងចែករំលែកនិងរបស់ប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តដែលមានបំណងទទួលបានការចែករំលែក។

**មាត្រា២៨ .-**

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុដែលបានចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុត្រូវបន្តបំពេញកាតព្វកិច្ចនៃការប្រើប្រាស់ហ្វ្រេកង់វិទ្យុ ដូចមានចែងក្នុងអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុ។

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុដែលបានចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុត្រូវធានាថាប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តដែលទទួលបានការចែករំលែកបំពេញកាតព្វកិច្ចនៃការប្រើប្រាស់ហ្វ្រេកង់វិទ្យុ ដូចមានចែងក្នុងអនុក្រឹត្យនេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត រួមទាំងលក្ខខណ្ឌនៃអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុ។

**មាត្រា២៩ .-**

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់វិទ្យុដែលបានចែករំលែកសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុត្រូវជូនដំណឹងអំពីការឈប់ប្រើប្រាស់ហ្វ្រេកង់វិទ្យុមក **ន.ទ.ក**. យ៉ាងតិច៦០(ហុកសិប)ថ្ងៃ មុនកិច្ចព្រមព្រៀងចែករំលែកហ្វ្រេកង់វិទ្យុអស់សុពលភាពឬត្រូវបានរំលាយតាមករណីជាក់ស្តែង។

# ផ្នែកទី៧
# ការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុ

**មាត្រា៣០ .-**

ការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុត្រូវមានការអនុញ្ញាតជាមុនពី **ន.ទ.ក.** និងអនុវត្តបានចំពោះតែអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ ដោយគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដោយមានការទទួលស្គាល់ពី **ន.ទ.ក.**។

ខ- រយៈពេលនៃសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុដែលទទួលបានពីការផ្ទេរត្រូវដូចគ្នានឹងរយៈពេលដែលនៅសល់នៅក្នុងអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុដើមបន្ទាប់ពីកាត់រយៈពេលដែលប្រើប្រាស់រួច។

ក្នុងករណីដែលមានការអនុញ្ញាតឱ្យមានការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុ ដូចមានចែងក្នុងកថាខណ្ឌទី១ **ន.ទ.ក.** ត្រូវប្តូរឈ្មោះអ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុពីឈ្មោះអ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុដើមមកជាឈ្មោះអ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុបន្ត សម្រាប់រយៈពេលដែលនៅសល់។

បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា៣១ .-**

ប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តដែលទទួលបានសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុតាមរយៈការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុត្រូវបង់កម្រៃចូលថវិកាជាតិ ដូចខាងក្រោម៖

ក- ១០% (ដប់ភាគរយ) នៃតម្លៃប្រេកង់វិទ្យុដែលទទួលបានតាមរយៈការដេញថ្លៃ ដោយសមាមាត្រទៅនឹងសុពលភាពនៃការប្រើប្រាស់ ចំពោះប្រេកង់វិទ្យុដែលអ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុទទួលបានតាមរយៈការដេញថ្លៃ។

ខ- ៥០% (ហាសិបភាគរយ) នៃតម្លៃសេដ្ឋកិច្ចនៃប្រេកង់វិទ្យុ ចំពោះប្រេកង់វិទ្យុដែលអ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុទទួលបានតាមរយៈការមិនដេញថ្លៃ។

តម្លៃសេដ្ឋកិច្ចនៃប្រេកង់វិទ្យុត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣២ .-**

ប្រតិបត្តិករផ្តល់សេវាទូរសព្ទចល័តដែលទទួលបានសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុតាមរយៈការផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុ ត្រូវបន្តអនុវត្តកាតព្វកិច្ចនៃការប្រើប្រាស់ប្រេកង់វិទ្យុដូចមានចែងក្នុងលក្ខខណ្ឌនៃអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

# ផ្នែកទី៨
# ការកែប្រែការប្រើប្រាស់ប្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរបច្ចេកវិទ្យា

**មាត្រា៣៣ .-**

អ្នកកាន់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុអាចកែប្រែការប្រើប្រាស់ប្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរនៃបច្ចេកវិទ្យាបាននិងគោរពទៅតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណប្រតិបត្តិការសេវាទូរសព្ទចល័តតាមរយៈការដាក់ពាក្យសុំការអនុញ្ញាតពី **ន.ទ.ក.**។

**ន.ទ.ក.** ត្រូវពិនិត្យនិងសម្រេចលើពាក្យស្នើសុំកែប្រែការប្រើប្រាស់ប្រេកង់វិទ្យុក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ ដោយពិចារណាលើលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ផែនការធុរកិច្ចនិងផែនការបច្ចេកទេសថ្មីត្រូវស្របនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត រួមទាំងផែនការជាតិវិសាលគមន៍ហ្វ្រេកង់វិទ្យុ។
ខ- ការវិវឌ្ឍនៃបច្ចេកវិទ្យានៅតាមប្រទេសក្នុងតំបន់និងពិភពលោក។
គ- ផលប្រយោជន៍នៃសេវាឬបច្ចេកវិទ្យាថ្មីសម្រាប់អ្នកប្រើប្រាស់។
ឃ- តម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។

បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការកែប្រែការប្រើប្រាស់ហ្វ្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរនៃបច្ចេកវិទ្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

កម្រៃនៃការស្នើសុំកែប្រែការប្រើប្រាស់ហ្វ្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរបច្ចេកវិទ្យា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៩
## ការព្យួរនិងការដកហូតអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុ

**មាត្រា៣៤ .-**

អាជ្ញាបណ្ណហ្វ្រេកង់វិទ្យុអាចត្រូវបានព្យួរក្នុងករណីដែលអ្នកកាន់អាជ្ញាបណ្ណហ្វ្រេកង់វិទ្យុនោះមិនបានបំពេញកាតព្វកិច្ចណាមួយដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២២នៃអនុក្រឹត្យនេះ ឬប្រើប្រាស់ហ្វ្រេកង់វិទ្យុនោះពុំមានប្រសិទ្ធភាពដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ឬបង្កការរំខានធ្ងន់ធ្ងរហើយមិនធ្វើការដោះស្រាយតាមការណែនាំរបស់ **ន.ទ.ក.** ឬបំពានលើលក្ខខណ្ឌផ្សេងទៀតនៃអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុ។

**មាត្រា៣៥ .-**

ដើម្បីអនុវត្តផែនការជាតិវិសាលគមន៍ហ្វ្រេកង់វិទ្យុ សិទ្ធិប្រើប្រាស់បន្ទារហ្វ្រេកង់វិទ្យុមួយផ្នែកឬទាំងស្រុងដែលត្រូវបានផ្តល់អាចត្រូវបានដកហូតដោយ **ន.ទ.ក.** ស្របតាមការសម្រេចរបស់ **ក.ប.ទ.**។

ក្រៅពីលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ការដកហូតសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុក៏ត្រូវអនុវត្តក្នុងករណី ដូចខាងក្រោម៖

ក- ប្រើប្រាស់ហ្វ្រេកង់វិទ្យុក្នុងគោលបំណងប្រព្រឹត្តបទល្មើសប្រឆាំងនឹងជាតិ។
ខ- បង្កើតឬផ្សាយស៊ីញ៉ាល់រំខានដល់ប្រតិបត្តិការបរិធានហ្វ្រេកង់វិទ្យុឬធ្វើឱ្យឆ្លងរំខានដល់ប្រព័ន្ធទូរគមនាគមន៍ផ្សេងទៀត។
គ- ផ្តល់ព័ត៌មានក្លែងក្លាយដើម្បីទទួលបានអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុ។
ឃ- មិនបានបង់ថ្លៃប្រើប្រាស់ហ្វ្រេកង់វិទ្យុទៅតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ។
ង- ក្ស័យធនមិនអាចផ្តល់សេវាតទៅទៀតបានឬរំលាយអាជីវកម្ម។
ច- បំពានលក្ខខណ្ឌនៃអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុ។

**មាត្រា៣៦ .-**

**ន.ទ.ក.** ត្រូវចេញសេចក្តីសម្រេចព្យួរឬដកហូតសិទ្ធិប្រើប្រាស់ហ្វ្រេកង់វិទ្យុ ស្របតាមការសម្រេចរបស់ **ក.ប.ទ.**។ សេចក្តីសម្រេចនេះត្រូវផ្សព្វផ្សាយជាសាធារណៈ។

បុគ្គលណាដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ **ន.ទ.ក.** អាចប្តឹងតវ៉ាក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ទៅ **ក.ប.ទ.** គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

រដ្ឋមន្ត្រី **ក.ប.ទ.** ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។ ក្នុងករណីបុគ្គលប្តឹងតវ៉ាមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ទ.** បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីច្បាប់ជាធរមាន ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការព្យួរនិងការដកហូតអាជ្ញាបណ្ណហ្វ្រេកង់វិទ្យុត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

# ផ្នែកទី១០
# ការប្រើប្រាស់ប្រេកង់វិទ្យុក្នុងករណីប្រធានសក្តិ ឬប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

**មាត្រា៣៧ .-**

**ក.ប.ទ.** អាចបញ្ជាអ្នកកាន់អាជ្ញាបណ្ណប្រេកង់វិទ្យុដែលពាក់ព័ន្ធឱ្យចាត់វិធានការចាំបាច់ដោយផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងករណីប្រធានសក្តិឬប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

# ជំពូកទី៦
# បន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណប

**មាត្រា៣៨ .-**

សិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្នុងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណប ត្រូវសម្រេចដោយរាជរដ្ឋាភិបាលដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។ សិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្នុងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណប មានសុពលភាពពី ៥(ប្រាំ)ឆ្នាំទៅ ១៥(ដប់ប្រាំ)ឆ្នាំ ស្របតាមចរិតលក្ខណៈនៃផ្កាយរណប ចាប់ពីថ្ងៃដែលបានបាញ់បង្ហោះផ្កាយរណបចូលគន្លងដោយជោគជ័យលើកទីមួយ។

អ្នកទទួលសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្នុងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណបដែលបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណឬតាមកិច្ចសន្យា អាចមានសិទ្ធិស្នើសុំបន្តការប្រើប្រាស់តែមួយដងគត់សម្រាប់រយៈពេលយ៉ាងយូរ ៥(ប្រាំ)ឆ្នាំ។

អ្នកទទួលសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្នុងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណបពុំអាចផ្ទេរសិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុនៅក្នុងបន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណបទៅបុគ្គលផ្សេងដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ឡើយ។

**មាត្រា៣៩ .-**

បុគ្គលដែលអាចទទួលសិទ្ធិប្រើប្រាស់បន្ទារប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងគន្លងផ្កាយរណបត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

ក- មានប្រតិបត្តិការស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- មានសមត្ថភាពគ្រប់គ្រាន់ខាងហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដើម្បីគ្រប់គ្រងនិងប្រតិបត្តិការផ្កាយរណប។

គ- មានផែនការប្រើប្រាស់គន្លងផ្កាយរណបប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងចំគោលដៅនៃប្រេកង់វិទ្យុនិងប្រតិបត្តិការដែលអនុញ្ញាតដោយច្បាប់។

ឃ- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌនៃអាជ្ញាបណ្ណ។

បែបបទ លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ការអនុញ្ញាតនិងប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់ផ្កាយរណបនិងការប្រើប្រាស់គន្លងផ្កាយរណប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

# ជំពូកទី៧
# គោលការណ៍នៃការធ្វើផែនការបរិវត្តន៍វិសាលគមន៍ប្រេកង់វិទ្យុ

**មាត្រា៤០ .-**

ផែនការបរិវត្តន៍វិសាលគមន៍ប្រេកង់វិទ្យុត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖

ក- ផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ខ- ទីផ្សារទូរគមនាគមន៍និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៃព្រះរាជាណាចក្រកម្ពុជា។

គ- ការអភិវឌ្ឍនៃបច្ចេកវិទ្យា។

**មាត្រា៤១ .-**

ផែនការបរិវត្តន៍វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុត្រូវកំណត់អំពី៖

ក- គោលបំណងនិងគុណប្រយោជន៍នៃផែនការបរិវត្តន៍។

ខ- ប្រភេទសេវាដែលជាកម្មវត្ថុនៃផែនការបរិវត្តន៍វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ។

គ- ទីតាំងនិងទំហំបន្ទារហ្វ្រេកង់ស៍វិទ្យុ។

ឃ- រយៈពេលអន្តរកាលនៃការផ្លាស់ប្តូរ។

ង- ដំណោះស្រាយលើផលប៉ះពាល់ដោយសារផែនការបរិវត្តន៍វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ។

ផែនការបរិវត្តន៍វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុត្រូវដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៨

## គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍

**មាត្រា៤២ .-**

អ្នកកាន់អាជ្ញាបណ្ណហ្វ្រេកង់ស៍វិទ្យុទាំងអស់និងអ្នកប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ដែលស្ថិតនៅក្រោមការអនុញ្ញាតឱ្យប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុទូទៅ ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ ត្រូវប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ដែលមានវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនិងតែមប្រើប្រាស់បច្ចេកទេសពី **ន.ទ.ក.** ស្របតាមបទដ្ឋានបច្ចេកទេសគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា៤៣ .-**

បុគ្គលដែលស្នើសុំអាជ្ញាបណ្ណបរិជានហ្វ្រេកង់ស៍វិទ្យុដែលមានភ្ជាប់លក្ខខណ្ឌនៃការបណ្តុះបណ្តាលត្រូវចូលរួមវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍និងទទួលបានការទទួលស្គាល់គុណវុឌ្ឍិតាមការកំណត់របស់ **ន.ទ.ក.** ជាមុន។

បុគ្គលដែលដំឡើងគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ត្រូវមានគុណវុឌ្ឍិដែលទទួលស្គាល់ដោយ **ន.ទ.ក.**។

បែបបទនិងលក្ខខណ្ឌនៃការបណ្តុះបណ្តាលនិងការទទួលស្គាល់គុណវុឌ្ឍិនៃការប្រើប្រាស់និងការដំឡើងគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៩

## ការសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុតាមបណ្តោយព្រំដែន

**មាត្រា៤៤ .-**

ការសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាងត្រូវផ្អែកលើគោលការណ៍ដូចខាងក្រោម៖

ក- ប្រសិទ្ធភាពនៃការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុ។

ខ- ការមិនរំខានដល់ការទទួលស៊ីញ៉ាល់។

គ- ការពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាបណ្ណហ្វ្រេកង់ស៍វិទ្យុ។

**មាត្រា៤៥ .-**

**ក.ប.ទ.** និង **ន.ទ.ក.** ត្រូវចូលរួមកិច្ចប្រជុំសម្របសម្រួលទ្វេភាគីឬពហុភាគី អំពីការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុតាមបណ្តោយព្រំដែន ដោយរួមបញ្ចូលទាំង៖

ក- ការរៀបចំកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគីដែលទាក់ទងនឹងការសម្របសម្រួលបច្ចេកទេស ការប្រើប្រាស់ហ្វ្រេកង់សវិទ្យុតាមបណ្ដោយព្រំដែន និងការកាត់បន្ថយការឆ្លងរំខានឱ្យនៅកម្រិតអប្បបរមា។ កិច្ចព្រមព្រៀងនេះមិនមានផលប៉ះពាល់ដល់ការខណ្ឌសីមាព្រំដែនរវាងរដ្ឋនិងរដ្ឋឡើយ។

ខ- ការរៀបចំវិធានដោយឡែកស្ដីពីគោលការណ៍ណែនាំនិងបទដ្ឋានបច្ចេកទេសសម្រាប់ការសម្របសម្រួល ការប្រើប្រាស់ហ្វ្រេកង់សវិទ្យុតាមបណ្ដោយព្រំដែន ស្របតាមគោលនយោបាយនិង/ឬផែនការជាតិវិសាលគមន៍ហ្វ្រេកង់សវិទ្យុ។

## ជំពូកទី១០
## អធិការកិច្ចលើការប្រើប្រាស់ហ្វ្រេកង់សវិទ្យុ

**មាត្រា៤៦ .-**

**ន.ទ.ក.** ត្រូវតាមដាននិងត្រួតពិនិត្យជាប្រចាំចំពោះការប្រើប្រាស់ហ្វ្រេកង់សវិទ្យុគ្រប់ប្រភេទ។

ការធ្វើអធិការកិច្ចលើការប្រើប្រាស់ហ្វ្រេកង់សវិទ្យុត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដូចមានចែងក្នុងជំពូកទី១៣នៃច្បាប់ស្ដីពីទូរគមនាគមន៍។

## ជំពូកទី១១
## ការប្ដឹងតវ៉ានិងការដោះស្រាយវិវាទ ពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់សវិទ្យុ

**មាត្រា៤៧ .-**

បុគ្គលណាដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ **ន.ទ.ក.** ក្រៅពីបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣៦នៃអនុក្រឹត្យនេះ អាចប្ដឹងតវ៉ាក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា តាមនីតិវិធីជាធរមាន។

**មាត្រា៤៨ .-**

នៅពេលមានវិវាទពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់សវិទ្យុ ភាគីវិវាទត្រូវធ្វើការផ្សះផ្សាដោយសន្តិវិធីក្រោមកិច្ចសម្របសម្រួលពី **ន.ទ.ក.** ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់និងធានាការពារផលប្រយោជន៍សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្សះផ្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

ក្នុងករណីពុំមានការសះជា ភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តការឬតុលាការមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤៩ .-**

កម្រៃសេវាសម្រាប់ការផ្សះផ្សាវិវាទ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១២
## ទណ្ឌកម្ម

**មាត្រា៥០ .-**

បុគ្គលដែលបំពានបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវទទួលទណ្ឌកម្មរដ្ឋបាលនិង/ឬទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី១៣
## អន្តរប្បញ្ញត្តិ

**មាត្រា៥១ .-**

បុគ្គលដែលបានទទួលសិទ្ធិប្រើប្រាស់ហ្វ្រេកង់សវិទ្យុសម្រាប់ដំណើរការសេវាទូរសព្ទចល័តតាមរយៈអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់សវិទ្យុនិងបុគ្គលដែលបានទទួលសិទ្ធិប្រើប្រាស់ហ្វ្រេកង់សវិទ្យុសម្រាប់ដំណើរការ

សេវាទូរសព្ទចល័តតាមរយៈអាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទចល័ត មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុថ្មីដោយមិនបង់ថ្លៃសម្រាប់ការចេញអាជ្ញាបណ្ណដោយ **ន.ទ.ក.** ក្នុងរយៈពេល ១(មួយ)ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ។

ការផ្តល់អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុថ្មីសម្រាប់ដំណើរការសេវាទូរសព្ទចល័ត ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍បង្កើនប្រសិទ្ធភាពរួមប្រើប្រាស់ប្រេកង់វិទ្យុ និងការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍តាមការសម្រេចរបស់រាជរដ្ឋាភិបាល យោងសំណើរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។ បុគ្គលដែលបានទទួលអាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុដូចកំណត់ក្នុងកថាខណ្ឌនេះ ត្រូវបង់កម្រៃប្រចាំឆ្នាំដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ។

**មាត្រា៥២.-**

លិខិតអនុញ្ញាតប្រើប្រាស់ប្រេកង់វិទ្យុVHFនិងUHF ដែលចេញដោយមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវរក្សាសុពលភាពនៅដដែលរហូតដល់ពេលអស់សុពលភាព ហើយលិខិតអនុញ្ញាតប្រភេទនេះត្រូវជំនួសវិញដោយអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា៥៣.-**

អាជ្ញាបណ្ណប្រេកង់វិទ្យុដូចខាងក្រោមដែលចេញដោយ **ន.ទ.ក.** មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវរក្សាសុពលភាពនៅដដែល៖

ក- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវិទ្យុអាម៉ាទ័រ។

ខ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងគ្រប់ប្រភេទ។

គ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវិទ្យុផ្សាយសំឡេងគ្រប់ប្រភេទ។

ឃ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយទូរទស្សន៍គ្រប់ប្រភេទ។

ង- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវិទ្យុម៉ៃក្រូវ៉េវ។

ច- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវិទ្យុប្រដប៊ែន។

ឆ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការស្ថានីយវីសាត។

ជ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការទូរសព្ទនិងស្ថានីយផ្កាយរណប។

ឈ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការផ្តល់សេវាទូរសព្ទអចល័តឥតប្រើខ្សែ។

ញ- អាជ្ញាបណ្ណប្រេកង់វិទ្យុសម្រាប់ដំណើរការវិទ្យុប្រើប្រាស់ប្រេកង់ប្រដប៊ែនលើយន្តហោះឆ្លងកាត់ផ្ទៃអាកាសកម្ពុជា។

អាជ្ញាបណ្ណប្រេកង់វិទ្យុដូចមានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ នឹងត្រូវជំនួសដោយអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ ចាប់ពីថ្ងៃអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី១៤

## អវសានប្បញ្ញត្តិ

**មាត្រា៥៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៤ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២៣
ស្តីពីការរៀបចំ ការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ

# សទ្ទានុក្រម

| | |
|---|---|
| ១- ករណីប្រធានសក្តិ<br>Force Majeure | សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈដែលមិនបានគ្រោងទុកនិងមិនអាចគ្រប់គ្រងបានដោយបុគ្គល ស្របតាមការកំណត់នៃបទប្បញ្ញត្តិជាធរមាន។ |
| ២- ការកែប្រែការប្រើប្រាស់ប្រេកង់វិទ្យុស្របតាមការផ្លាស់ប្តូរបច្ចេកវិទ្យា<br>Refarming | សំដៅដល់ការផ្លាស់ប្តូរបច្ចេកវិទ្យានៃការប្រើប្រាស់ប្រេកង់វិទ្យុដែលកំពុងដំណើរការបច្ចុប្បន្នដោយបច្ចេកវិទ្យាថ្មីនៃការប្រើប្រាស់ប្រេកង់វិទ្យុនេះដែលអាចធ្វើឱ្យការប្រើប្រាស់ប្រេកង់វិទ្យុនេះមានប្រសិទ្ធភាពខ្ពស់ជាងមុន។ |
| ៣- ការដេញថ្លៃ<br>Auction | សំដៅដល់ដំណើរប្រព្រឹត្តទៅនៃការប្រកាសស្វែងរកអ្នកប្រើប្រាស់ប្រេកង់វិទ្យុ ការដាក់ពាក្យសុំប្រើប្រាស់ប្រេកង់វិទ្យុ និងការសម្រេចផ្តល់សិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុទៅតាមទម្រង់ លក្ខខណ្ឌ និងនីតិវិធីដែលមានកំណត់ក្នុងអនុក្រឹត្យនេះឬបទប្បញ្ញត្តិ/បទដ្ឋានជាធរមាន។ |
| ៤- ការដំឡើង<br>Installment | សំដៅដល់ការដំឡើង ការផ្លាស់ប្តូរ ឬការបំពាក់បន្ថែមគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍។ |
| ៥- ការប្រើប្រាស់ប្រេកង់វិទ្យុពុំអស់លទ្ធភាព<br>Non-Exhaustive Use of the Granated Radio Frequency Bandwidth | សំដៅដល់ការប្រើប្រាស់ប្រេកង់វិទ្យុស្របច្បាប់ តែមិនឆ្លើយតបទៅតាមការកំណត់របស់អាជ្ញាបណ្ណប្រេកង់វិទ្យុឬមានសន្ទស្សន៍នៃការប្រើប្រាស់ប្រេកង់វិទ្យុ (ផលចែករវាងចំនួនCellសរុបដែលប្រើប្រាស់បន្ទារប្រេកង់វិទ្យុជាមួយទំហំបន្ទាររបស់វា) ទាបជាង២/៣សន្ទស្សន៍នៃការប្រើប្រាស់ប្រេកង់វិទ្យុខ្ពស់បំផុតរបស់ប្រតិបត្តិករទាំងអស់ ឬប្រើប្រាស់បន្ទារប្រេកង់វិទ្យុតិចជាង២/៣នៃទំហំបន្ទារដែលបានផ្តល់ឱ្យឬភាពរវល់នៃការប្រើប្រាស់ប្រេកង់វិទ្យុតិចជាង១/៣នៃពេលវេលាប្រចាំថ្ងៃ។ |
| ៦- ការឆ្លងរំខាន<br>Interference | សំដៅដល់ផលប៉ះពាល់នៃថាមពលដែលមិនចាំបាច់ ដែលបង្កដោយការសាយភាយការផ្សាយឬការឆ្លងបន្ទុកអគ្គិសនី(induction) ដែលរំខានដល់ការទទួលយកស៊ីញ៉ាល់នៃប្រព័ន្ធទូរគមនាគមន៍ដែលនាំឱ្យមានការថយចុះនូវដំណើរការឬការទទួលយកព័ត៌មានឬទិន្នន័យ។ ការឆ្លងរំខានមានបីប្រភេទ រួមមាន : ការឆ្លងរំខានដែលអនុញ្ញាត (Permissible Interference) ការឆ្លងរំខានដែលអាចទទួលយកបាន (Acceptable Interference) និងការឆ្លងរំខានធ្ងន់ធ្ងរ (Harmful Interference)។ |

| | |
|---|---|
| ៧- ការឆ្លងរំខានដែលអនុញ្ញាត<br>Permissible Interference | សំដៅដល់ការរំខានដែលអាចវាស់ស្ទង់ឬព្យាករបាន តែត្រូវបានអនុញ្ញាតដោយត្រូវអនុវត្តតាមលក្ខខណ្ឌបច្ចេកទេសនៃការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍នៃសេវាដែលមានកំណត់នៅក្នុងតារាងជាតិវិសាលគមន៍ប្រេកង់វិទ្យុ សេចក្តីណែនាំរបស់ITU-R ឬកិច្ចព្រមព្រៀងពិសេសនៃការប្រើប្រាស់ប្រេកង់វិទ្យុណាមួយ។ |
| ៨- ការឆ្លងរំខានដែលអាចទទួលយកបាន<br>Acceptable Interference | សំដៅដល់ការរំខានដែលអាចមានផលប៉ះពាល់ខ្ពស់ជាងការំខានដែលអនុញ្ញាត (Permissible Interference) តែត្រូវបានព្រមព្រៀងទទួលយកដោយភាគីដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍។ |
| ៩- ការឆ្លងរំខានធ្ងន់ធ្ងរ<br>Harmful Interference | សំដៅដល់ការរំខានដែលនាំឱ្យមានគ្រោះថ្នាក់ដល់ដំណើរការជាធម្មតានៃសេវាទូរគមនាគមន៍ស្វែងរកទីតាំង ឬសេវាសុវត្ថិភាពណាមួយ ឬដែលនាំឱ្យថមថយ រាំងស្ទះ ជ្រៀតជ្រែក ឬបង្កភាពអាក់រអួលញឹកញាប់ដល់សេវាទូរគមនាគមន៍ណាមួយដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ស្របច្បាប់ក្នុងដែនសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។ |
| ១០- ការអនុញ្ញាតឱ្យប្រើប្រាស់ប្រេកង់វិទ្យុទូទៅ<br>General Authorization/ Class License/ Unlicensed Spectrum | សំដៅដល់ការអនុញ្ញាតឱ្យប្រើប្រាស់ប្រេកង់វិទ្យុសម្រាប់ផ្នែកឧស្សាហកម្ម វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ(ISM) ឬដែលប្រើប្រាស់ថាមពលតិចនិងកំណត់ជាក់លាក់ជាស្រេចនៅក្នុងលក្ខណៈបច្ចេកទេសលម្អិតនៃគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍នីមួយៗ ដោយស្របនឹងផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុនិងផែនការបន្ទាប្រេកង់វិទ្យុ ដោយពុំចាំបាច់មានអាជ្ញាបណ្ណប្រេកង់វិទ្យុ។ |
| ១១- គន្លងផ្កាយរណបអចល័តធៀបនឹងធរណី<br>Geostationary Orbits | សំដៅដល់គន្លងគោចរដែលមានទីតាំងនៅចម្ងាយប្រមាណ ៣៥ ៧៨៦គ.ម. ពីលើកម្ពស់ទឹកសមុទ្រ ចំពីលើខ្សែអេក្វាទ័រ មានទិសបង្វិលដូចគ្នានឹងទិសបង្វិលរបស់ផែនដី និងមានល្បឿនបង្វិលប្រមាណជា៣គ.ម. ក្នុង១វិនាទី វិលស្របនឹងផែនដី ដែលធ្វើឱ្យវានៅនឹងថ្កល់មួយកន្លែងធៀបនឹងផែនដី។ |
| ១២- គន្លងផ្កាយរណបចល័តធៀបនឹងធរណី<br>Non-Geostationary Orbits | សំដៅដល់គន្លងគោចរដែលមានទីតាំងនៅចម្ងាយឆ្ងាយជាងឬជិតជាង ៣៥ ៧៨៦ គ.ម. ពីលើកម្ពស់ទឹកសមុទ្រនិងមានល្បឿនបង្វិលយឺតជាងឬលឿនជាងល្បឿនបង្វិលផែនដី។ គន្លងធរណីចល័ត រួមមានជាអាទិ៍ គន្លងធរណីចល័តក្លាក(Clarke)(ប្រមាណ២៦៥ ០០០ គ.ម.) គន្លងធរណី ចល័តកម្ពស់មធ្យម (ចន្លោះប្រមាណពី២ ០០០ គ.ម. ទៅ៣៥ ៧៨៦គ.ម.) និងគន្លងធរណីចល័តកម្ពស់ទាប(ចន្លោះប្រមាណពី១៦០ គ.ម. ទៅ២ ០០០ គ.ម.)។ |

១៣- គន្លងផ្កាយរណប
Satellite Orbit

សំដៅដល់គន្លងគោចរសម្រាប់ឱ្យផ្កាយរណបធ្វើដំណើរតាមដែលក្នុងនោះត្រូវបានបែងចែកជាពីរក្រុមសំខាន់ៗគឺ គន្លងផ្កាយរណបអចល័តធៀបធរណីនិងគន្លងផ្កាយរណបចល័តធៀបនឹងធរណី។

១៤- តារាងជាតិបែងចែកហ្វ្រេកង់សវិទ្យុ
National Frequency Allocation Table-NFAT

សំដៅដល់តារាងនៃការបែងចែកវិសាលគមន៍ហ្វ្រេកង់សវិទ្យុដែលត្រូវរៀបចំឡើងស្របតាមមាត្រា៧នៃអនុក្រឹត្យនេះ ក្នុងគោលបំណងកំណត់ការប្រើប្រាស់ហ្វ្រេកង់សវិទ្យុសម្រាប់ផ្តល់សេវាវិទ្យុគមនាគមន៍នានា ដោយមានលក្ខខណ្ឌប្រើប្រាស់ច្បាស់លាស់។

១៥- តារាងពិពណ៌នាហ្វ្រេកង់សវិទ្យុ
Frequency Chart

សំដៅដល់តារាងព័ត៌មានហ្វ្រេកង់សវិទ្យុ ដែលត្រូវបានបង្ហាញតាមរយៈខ្សែបន្ទាត់ពណ៌ត្រង់ឬកោង(Chart) ដែលអធិប្បាយរៀបរាប់អំពីទំនាក់ទំនងរវាងបន្ទារហ្វ្រេកង់សវិទ្យុនិងផែនការប្រើប្រាស់ហ្វ្រេកង់សវិទ្យុ។

១៦- ទំហំបន្ទារ
Bandwidth

សំដៅដល់ផលសងរវាងហ្វ្រេកង់សវិទ្យុខ្ពស់បំផុតនិងទាបបំផុតដែលកំណត់ទីតាំងរបស់បន្ទារ។

១៧- ទីតាំងនៃបន្ទារហ្វ្រេកង់សវិទ្យុ
Position of the Radio Frequency Band

សំដៅដល់ទីតាំងដែលបានកំណត់ដោយហ្វ្រេកង់សវិទ្យុខ្ពស់បំផុតនិងទាបបំផុត។

១៨- បុគ្គល
Person

សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។

១៩- បញ្ជីអន្តរជាតិគោលហ្វ្រេកង់សវិទ្យុ
Master International Frequency Register-MIFR

សំដៅដល់បញ្ជីទិន្នន័យនៃការប្រើប្រាស់ហ្វ្រេកង់សវិទ្យុរបស់រដ្ឋសមាជិកដែលបានចុះបញ្ជីជាផ្លូវការនៅសហភាពទូរគមនាគមន៍អន្តរជាតិ(ITU)។

២០- បន្ទារហ្វ្រេកង់សវិទ្យុ
Radio Frequency Band

សំដៅដល់អនុលម្ពនៃវិសាលគមន៍ហ្វ្រេកង់សវិទ្យុដែលត្រូវបានបែងចែកទៅតាមប្រភេទនៃការប្រើប្រាស់។ ឧទាហរណ៍ បន្ទារហ្វ្រេកង់សវិទ្យុ/បន្ទារហ្វ្រេកង់ស៧០០MHz សំដៅដល់អនុលម្ពចន្លោះពី៦៩៨MHz ដល់៨០៦MHz ត្រូវបានឱ្យប្រើប្រាស់សម្រាប់សេវាទូរគមនាគមន៍ចល័តអន្តរជាតិ (IMT-2020) នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកនិងពិភពលោក។

២១- បន្ទារហ្វ្រេកង់សវិទ្យុបម្រុង
Reserved Radio Frequency Band

សំដៅដល់បន្ទារហ្វ្រេកង់សវិទ្យុដែលត្រូវបានបម្រុងទុកសម្រាប់ការប្រើប្រាស់ក្នុងករណីបន្ទាន់ឬចាំបាច់ណាមួយ ស្របតាមបច្ចេកវិទ្យានាពេលអនាគត។

២២- បន្ទារហ្វ្រេកង់សវិទ្យុផ្កាយរណប
Satellite Radio Frequency Band

សំដៅដល់បន្ទារហ្វ្រេកង់សវិទ្យុដែលបម្រុងទុកសម្រាប់ប្រើប្រាស់ជាមួយផ្កាយរណប។ បន្ទារហ្វ្រេកង់សវិទ្យុទាំងនោះរួមមាន ជាអាទិ៍ បន្ទារហ្វ្រេកង់សវិទ្យុ L-band, S-band, C-band, X-band, Ku-band, K-band, Ka-band ។ល។

**២៣- ប៉ារ៉ាម៉ែត្របច្ចេកទេសនៃការផ្សាយ**
**Emission Parameters**

សំដៅដល់ប៉ារ៉ាម៉ែត្របច្ចេកទេស ដែលរួមមានជាអាទិ៍កម្លាំងផ្សាយ (Transmitted Power) ហ្វ្រេកង់ស៍ផ្សាយ (Transmitted Frequency) ទំហំបន្ទារ (Bandwidth) ប្រភេទម៉ូឌុលកម្ម (Modulation Type) ប្រភេទអង់តែន (Antenna Type) ទម្រង់នៃការសាយភាយដែនអេឡិចត្រូម៉ាញ៉េទិកតាមទិសដេក/បញ្ឈរ (Horizontal/Vertical Radiation Pattern) កម្ពស់បង្គោលអង់តែន (Antenna Tower Height) ប្រវែងអង់តែន (Antenna Height) ការតម្រង់ទិសនៃអង់តែនតាមទិសដេក/បញ្ឈរ (Antenna Orientation Horizontal/Vertical) ហ្វ្រេកង់ស៍ប្រតិបត្តិការរបស់អង់តែន (Antenna Operating Frequency)។

**២៤- ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**
**State of Emergency**

សំដៅដល់ភាពអាសន្នដែលអាចកើតឡើងនៅពេលដែលប្រជាជាតិប្រឈមនឹងគ្រោះថ្នាក់ ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរដែលគំរាមកំហែងឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

**២៥- ផែនការបរិវត្តន៍វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ**
**Conversion Plan**

សំដៅដល់ផែនការនៃការផ្លាស់ប្តូរពីអាជ្ញាបណ្ណប្រតិបត្តិការចាស់ឬ/និងអាជ្ញាបណ្ណហ្វ្រេកង់ស៍ចាស់ ឬជាផែនការនៃការផ្លាស់ប្តូរពីអាជ្ញាបណ្ណបរិធានហ្វ្រេកង់ស៍វិទ្យុទៅជាអាជ្ញាបណ្ណវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ។

**២៦- ផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ**
**National Radio Frequency Spectrum Plan**

សំដៅដល់ផែនការជាតិដែលរៀបចំឡើងស្របតាមមាត្រា៧នៃអនុក្រឹត្យនេះដើម្បីបែងចែកការប្រើប្រាស់ធនធានវិសាលគមន៍វិទ្យុទៅតាមប្រភេទសេវាវិទ្យុគមនាគមន៍នីមួយៗ ស្របតាមបទប្បញ្ញត្តិជាតិនិងវិទ្យុគមនាគមន៍អន្តរជាតិ (Radio Regulation) របស់សហភាពទូរគមនាគមន៍អន្តរជាតិ។

**២៧- ផែនការបន្ទារហ្វ្រេកង់ស៍វិទ្យុ**
**Frequency Band Plan**

សំដៅដល់ផែនការដែលរៀបចំឡើងស្របតាមមាត្រា៨នៃអនុក្រឹត្យនេះដើម្បីកំណត់ចន្លោះបន្ទារហ្វ្រេកង់ស៍វិទ្យុ ដែលត្រូវផ្តល់សម្រាប់សេវាមួយនិងបែងចែកជាចំនួនកាណាល់ជាក់លាក់ ស្របតាមផែនការជាតិវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុឬស្របតាមស្តង់ដាឬបទដ្ឋានបច្ចេកទេសតំបន់និងអន្តរជាតិ។

**២៨- វិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ**
**Radio Frequency Spectrum**

សំដៅដល់ចន្លោះលម្អដែលត្រូវគ្នានឹងចន្លោះលំយោលពី៣kHz (បីគីឡូអ៊ែត) ដល់៣ 000GHz (បីពាន់ជីកាអ៊ែត) និងដែលអនុញ្ញាតឱ្យថាមពលអេឡិចត្រូម៉ាញេទិកអាចចរ/សាយភាយ/ផ្សាយពីកន្លែងមួយទៅកន្លែង មួយផ្សេងទៀត។

២៩- ស្ថានីយផ្កាយរណបលើដី
Earth/Terrestrial Stations
សំដៅដល់ស្ថានីយផ្កាយរណបដែលបានដំឡើងនៅលើដី ដើម្បីទំនាក់ទំនងទៅផ្កាយរណបមួយឬច្រើនផ្សេងទៀត។

៣០- សេវាផ្សព្វផ្សាយសោតទស្សន៍
Broadcasting Service
សំដៅដល់សេវាវិទ្យុគមនាគមន៍ដែលបញ្ជូនកម្មវិធីផ្សាយ ដូចជាសំឡេង រូបភាព ឬវីដេអូ តាមរយៈវិទ្យុផ្សាយសំឡេងឬតាមរយៈទូរទស្សន៍ទៅកាន់សាធារណជន។

៣១- សេវាវិទ្យុសម្រាប់ប្រតិបត្តិការស្វែងរកទីតាំង
Radiodetermination Service
សំដៅដល់សេវាវិទ្យុគមនាគមន៍ដែលប្រើសម្រាប់ការកំណត់ទីតាំង ល្បឿននិង/ឬលក្ខណៈដទៃទៀតនៃវត្ថុឬការទទួលបាននូវព័ត៌មានដែលទាក់ទងនឹងប៉ារ៉ាម៉ែត្រទាំងនោះ ដោយប្រើប្រាស់លក្ខណៈដាលនៃរលកវិទ្យុ។ វាត្រូវបានបែងចែកជាពីរក្រុមគឺ វិទ្យុកំណត់ទីតាំងនិងវិទ្យុនាំផ្លូវ។

៣២- សេវាវិទ្យុកំណត់ទីតាំង
Radiolocation Service
សំដៅដល់សេវាវិទ្យុគមនាគមន៍សម្រាប់ប្រតិបត្តិការស្វែងរកទីតាំងដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីវិទ្យុនាំផ្លូវ។ ជាទូទៅ វាត្រូវបានប្រើប្រាស់ដើម្បីស្វែងរកវត្ថុបែបអសកម្ម ឧទាហរណ៍ដូចជារ៉ាដាសម្រាប់កំណត់ ទីតាំងនាវាសត្រូវ ឧបករណ៍រាវរកខ្សែក្រោមដី បំពង់ទឹក ជាដើម។

៣៣- សេវាវិទ្យុនាំផ្លូវ
Radionavigation Service
សំដៅដល់សេវាវិទ្យុគមនាគមន៍សម្រាប់ប្រតិបត្តិការស្វែងរកទីតាំងដែលត្រូវបានប្រើប្រាស់ដើម្បីនាំផ្លូវធ្វើដំណើរដោយរួមទាំងការព្រមានពីឧបសគ្គ។ ជាទូទៅ វាត្រូវបានប្រើប្រាស់ដើម្បីស្វែងរកវត្ថុបែបសកម្ម ឧទាហរណ៍ដូចជាការកំណត់ទីតាំងនៃវត្ថុដោយប្រើ GPS ការកំណត់ទីតាំងបង្គោលអង់តែនដោយប្រើប្រាស់ការស្វែងរកទិសដៅ (Direction Finding) ការកំណត់ទីតាំងជនរងគ្រោះដែលប្រើឧបករណ៍ស្វែងរកជំនួយតាមរលកវិទ្យុបែបភ្លើងនាំផ្លូវ (Beacon) ជាដើម។

៣៤- សេវាវិទ្យុគមនាគមន៍
Radiocommunication Service
សំដៅដល់សេវាដែលពាក់ព័ន្ធនឹងការផ្សាយ (Transmission) ការបំភាយរលកសញ្ញានិង/ឬការទទួលស៊ីញ៉ាល់ក្នុងគោលដៅទូរគមនាគមន៍ណាមួយ។

៣៥- សេវាវិទ្យុអាម៉ាទ័រ
Amateur Service
សំដៅដល់សេវាវិទ្យុគមនាគមន៍ដែលប្រើប្រាស់ក្នុងគោលបំណងស្វ័យបណ្តុះបណ្តាល ទំនាក់ទំនង ឬស្វែងយល់បច្ចេកទេសដែលអនុវត្តដោយអ្នកស្រាវជ្រាវមិនមែនជាអាជីព (Amateur) ដោយគ្មានគោលបំណងរកប្រាក់ចំណូល ដែលត្រូវបានអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ នេះ។

៣៦- ប្រេកង់វិទ្យុ
Radio Frequency
សំដៅដល់ចំនួនខួបអំពីទុតនៃការប្រែប្រួលរលកអេឡិចត្រូម៉ាញ៉េទិកក្នុងរយៈពេល១វិនាទីឬរលកអេឡិចត្រូម៉ាញ៉េទិកដែលសាយភាយក្នុងលម្ហអាកាសដោយគ្មានបំពង់នាំផ្លូវ។

| | |
|---|---|
| ៣៧- អ៊ែត/ហឺត<br>Hertz (Hz) | សំដៅដល់រង្វាស់ខ្នាតគំរូនៃរលកអេឡិចត្រូម៉ាញ៉េទិកក្នុងរយៈពេល ១វិនាទី ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ [kHz (kilohertz, $10^3$Hz); MHz (Megahertz, $10^6$Hz); GHz (Gigahertz, $10^9$Hz) and THz (Terahertz, $10^{12}$Hz)]។ |
| ៣៨- អាជ្ញាបណ្ណប្រេកង់វិទ្យុ<br>Frequency License | សំដៅដល់អាជ្ញាបណ្ណដែលបានផ្តល់ជូនដល់រូបវន្តបុគ្គលឬនីតិបុគ្គល សម្រាប់ប្រើប្រាស់បន្ទារប្រេកង់វិទ្យុ។ អាជ្ញាបណ្ណប្រេកង់វិទ្យុមានពីរប្រភេទគឺ អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុនិងអាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ។ |
| ៣៩- អាជ្ញាបណ្ណវិសាលគមន៍ប្រេកង់វិទ្យុ<br>Radio Frequency Spectrum License | សំដៅដល់អាជ្ញាបណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុផ្តាច់មុខស្របនឹងផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ ផែនការបន្ទារប្រេកង់វិទ្យុ ដោយមានបញ្ជាក់ទីតាំងបន្ទារប្រេកង់វិទ្យុ ទំហំបន្ទារប្រេកង់វិទ្យុ និងរយៈពេលប្រើប្រាស់ជាក់លាក់តាមរយៈការដេញថ្លៃដែលកំណត់ដោយរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |
| ៤០- អាជ្ញាបណ្ណបរិធានប្រេកង់វិទ្យុ<br>Radio Frequency Apparatus License | សំដៅដល់អាជ្ញាបណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ប្រេកង់វិទ្យុស្របនឹងផែនការជាតិវិសាលគមន៍ប្រេកង់វិទ្យុ ផែនការបន្ទារប្រេកង់វិទ្យុ ដែលមានរយៈពេលកំណត់ ទីកន្លែង ទីតាំងបន្ទារ ទំហំបន្ទារច្បាស់លាស់ និងកម្រៃត្រូវកំណត់ដោយរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដំណើរការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍។ |
| ៤១- បទដ្ឋានបច្ចេកទេស<br>Technical Standard | សំដៅដល់ស្តង់ដាបច្ចេកទេសនៃគ្រឿងសម្ភារៈបរិក្ខាទូរគមនាគមន៍។ |